# III- ការងារបណ្តាក្រសួង

## ១-ធនាគារជាតិនៃកម្ពុជា

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០

### ប្រកាសលេខ ធ ៧០០-៤៦ ប្រក.

### ស្តីពីអនុបាតសាធនភាពរបស់ធនាគារ

***

### ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

### សំរេច

**ប្រការ ១ :**

ធនាគារទាំងអស់ត្រូវពិនិត្យជាអចិន្ត្រៃយ៍ នូវអនុបាតសាធនភាពរបស់ខ្លួនអោយបានស្រប តាមបញ្ញត្តិនៃប្រកាសនេះ ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យឥណទាន សរុប មិនត្រូវតិចជាងម្ភៃភាគរយ (២០%) ឡើយ ។

**ប្រការ ២ :**

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃ ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ៣ :**

៣-១- ភាគបែងនៃអនុបាត គឺជាតំលៃទ្រព្យសកម្មសរុប (តំលៃសុទ្ធក្រោយពេលដក ចេញនូវសវិធានធននិងការរំលោះតំលៃ) និងខ្ទង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកំរិត

ហានិភ័យឥណទាន ។ ភាគដែលនេះមិនរាប់បញ្ចូលបម្រុងដែលបានដកចេញ ទៅ លើគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្ដីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

៣-២- ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម ៖

៣-២-១- ការថ្លឹងស្មូន្យភាគរយ (zero weighting) ចំពោះ ៖

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលបានធានាដោយប្រាក់បញ្ញើនៅធនាគារដដែល
- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ (Claims on sovereigns) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation ។

៣-២-២- ការថ្លឹង ២០% ចំពោះ ៖

- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation
- ឥណទេយ្យលើធនាគារ ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation ។

៣-២-៣- ការថ្លឹង ៥០% ចំពោះ ៖

- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation
- ឥណទេយ្យលើធនាគារ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation ។

៣-២-៤- ការថ្លឹង ១០០% ចំពោះ

- ទ្រព្យសកម្មដទៃទៀតទាំងអស់ ។

៣-៣- បញ្ញត្តិដូចតទៅនេះ នឹងត្រូវអនុវត្តចំពោះខ្ទង់ក្រៅតារាងតុល្យការ ៖

៣-៣-១- ខ្ទង់ក្រៅតារាងតុល្យការត្រូវបានចាត់ថ្នាក់ជា ៥ ប្រភេទ ស្របតាមតារាងដែលមានក្នុងឧបសម្ព័ន្ធ ។ ខ្ទង់ក្រៅតារាងតុល្យការទាំងនេះត្រូវបានយកមកគិត

- តាមតំលៃទាំងស្រុងរបស់វា នៅពេលបានចាត់ថ្នាក់ជាមានហានិភ័យទាំងស្រុង
- តាមតំលៃ ៥០% នៅពេលបានចាត់ថ្នាក់ជាមានហានិភ័យកំរិតមធ្យម

- តាមតំលៃ ២០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យគួនល្មម (Moderate risk)
- ខ្ចង់ដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាបមិនត្រូវបានយកមកគិតទេ ។

៣-៣-២- ចំនួនប្រាក់ដែលបានកំណត់ខាងលើ ត្រូវគុណជាមួយនឹងប្រភេទថ្លឹង ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៣-២ ដែលត្រូវអនុវត្តចំពោះប្រភេទនៃការថ្លឹង របស់អត្ថគាហកៈ ឬប្រភេទទ្រព្យសកម្មពាក់ព័ន្ធនោះ ។ ប៉ុន្តែ ៖

- ក្នុងករណីនៃការសន្យាដែលមានការធានាពីតតិយជន ការថ្លឹងគឺជាការថ្លឹងដែលអនុវត្តចំពោះអ្នកធានា ឬចំពោះអ្នកដែលត្រូវបានគេធានា
- ក្នុងករណីនៃការធានាចំពោះធនាគារមួយផ្សេងទៀតទាក់ទងដល់ការសងបំណុលដែលរក្សាទុកនៅធនាគារផ្សេងទៀតនោះ ការថ្លឹងជាការថ្លឹងដែលអនុវត្តចំពោះតំណាងទេយ្យទាំងនេះ ។

**ប្រការ ៤ :**

ធនាគារត្រូវប្រតិវេទអនុបាតសាធនភាពរបស់ខ្លួននៅ ថ្ងៃទី៣០ ខែមិថុនា និង ថ្ងៃទី៣១ ខែធ្នូជារៀងរាល់ឆ្នាំ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងអាចតំរូវអោយធនាគារណាមួយគណនាអនុបាតសាធនភាពរបស់ខ្លួន នៅកាលបរិច្ឆេទផ្សេងទៀត ស្របតាមការចាំបាច់នៃការត្រួតពិនិត្យ ។

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ក្នុងសារាចរ ពីតំរូសរាប់គណនាអនុបាត ដោយត្រូវប្រកាសពីខ្ទង់ទាំងឡាយក្នុងតំរូនេះ ។

ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ច្បាស់អំពីលក្ខណៈពិសេសរបស់ខ្ទង់ដែលត្រូវអនុវត្តការថ្លឹង ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ។

ធនាគារជាតិនៃកម្ពុជាអាចបដិសេធចំពោះការថ្លឹងដែលកំពុងអនុវត្តចំពោះទ្រព្យសកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ ប្រសិនបើគិតថាខ្ទង់នោះមិនអាចបំពេញតាមល័ក្ខខ័ណ្ឌជាធរមានបានដោយពេញចិត្តនោះទេ ។

**ប្រការ ៥ :**

ធនាគារជាតិនៃកម្ពុជាតំរូវអោយមានការយកចិត្តទុកដាក់ថា គោលនយោបាយគណនេយ្យខ្សោយ ឬ មិនគ្រប់គ្រាន់ធ្វើឲ្យអន្តរាយដល់សារៈប្រយោជន៍នៃកំរិតដើមទុន ដោយបង្កឲ្យមានអនុបាតសាធនភាពមិនត្រឹមត្រូវ ឬមិនអាចជឿបាន ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាចាត់ទុកថា

ការអនុវត្តន៍គណនេយ្យរឹងមាំ និងការវាយតំលៃត្រឹមត្រូវជាការសំខាន់ ជាពិសេស ចំពោះការចាត់ថ្នាក់ត្រឹមត្រូវនិងការធ្វើសវិធានធនទ្រព្យសកម្មតាមបញ្ញត្តិនៃប្រកាសស្តីពីចំណាត់ថ្នាក់និងការធ្វើសវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ ។

**ប្រការ ៦ :**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខា និងត្រា

**ជា ចាន់តូ**

★★★

## ឧបសម្ព័ន្ធនៃប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ ចំណាត់ថ្នាក់ខ្ទង់ក្រៅតារាងតុល្យការ ដែលមានចែង ក្នុងកថាខ័ណ្ឌ ៣-៣-១

***

ប្រតិបត្តិការទាំងឡាយណាដែលមិនមានចែងក្នុងតារាងខាងក្រោមនេះ ធនាគារត្រូវចាត់ថ្នាក់ខ្ទង់ទាំងនេះក្នុងប្រភេទប្រតិបត្តិការ ដែលមានលក្ខណៈស្រដៀងគ្នា បន្ទាប់ពីបានស្នើសុំធនាគារជាតិនៃកម្ពុជា ប្រសិនបើចាំបាច់ ។

១- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង

- ការធានាលើឥណទាន (ដកចេញហានិភ័យចំពោះអត្ថគាហកៈ)
- ការទទួលព្រម (acceptance)

- រូបិយបរិភាគ (endorsement) លើផលប័ត្រដែលមិនមានឈ្មោះរបស់ធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុមួយផ្សេងទៀត
- សកម្មភាពប្រតិបត្តិការដោយមានឧបាស្រ័យ (recourse)
- កំរិតឥណទានមិនអាចបដិសេធបាន (irrevocable credit line) ឬការធានា ដែលមានលក្ខណៈជំនួសឥណទាន ។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យខ្ពស់

២- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យមធ្យម

- ការសន្យាសងប្រាក់តាមឯកសារឥណទាន ដែលបានចេញផ្សាយឬបញ្ជាក់ហើយ នៅពេលដែលទំនិញមិនត្រូវបានប្រើជាវត្ថុបញ្ចាំ
- ការធានានិងសញ្ញាប័ណ្ណឧបត្ថម្ភ (warranties and indemnity bonds) (រួមទាំង tender, performance, customs and tax bonds) និងការធានាដែលមិនមានលក្ខណៈជំនួសឥណទាន
- កិច្ចសន្យាផ្តល់ឥណទានមិនទាន់ប្រើ ជាពិសេសឥណទានលើសសមតុល្យ (overdrrafts) និងការសន្យាអោយខ្ចីដែលមានកាល កំណត់លើសពីមួយឆ្នាំ
- ប្រតិបត្តិផ្សេងទៀតដែលមានហានិភ័យមធ្យម

៣- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យធួនល្មម

- ឯកសារឥណទានដែលត្រូវបានចេញផ្សាយឬបញ្ជាក់ហើយ ទំនិញត្រូវបានប្រើជាវត្ថុបញ្ចាំនិងប្រតិបត្តិការស្រដៀងគ្នាផ្សេងទៀត
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យធួនល្មម

៤- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាប

- ឥណទានមិនទាន់ប្រើប្រាស់ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាអោយខ្ចីដែលមានកាលកំណត់រហូតពេញមួយឆ្នាំ ឬដែលអាចលុបចោលដោយគ្មានល័ក្ខខ័ណ្ឌនៅពេលណាក៏បានដោយគ្មានការជូនដំណឹង ។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យទាប ។

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០

## ប្រកាសលេខ ធ ៧០០-៤៧ ប្រក.

## ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ

***

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៤៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំរេច

**ប្រការ ១ :**

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារត្រូវបានគណនាដូចតទៅ ៖

I- សរុប A ខ្ទង់ត្រូវបូក

- ដើមទុន ឬទាយជ្ជទានដើមទុន
- ទុនបំរុងក្រៅពីទុនបំរុងពីការវាយតំលៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការធនាគារ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ចំណេញរក្សាទុកសំរាប់វិនិយោគបន្ត (retained earnings)
- ចំណេញសុទ្ធ ដែលបានផ្ទៀងផ្ទាត់ហើយសំរាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ [១]
- ខ្ទង់ផ្សេងៗទៀត ដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា [២] ។

II- សរុប B ខ្ទង់ត្រូវដក

- ចំពោះភាគទុនិកៈ នាយក នាយកចាត់ការ និងសម្ព័ន្ធញាតិ
  - ចំណែកដើមទុនដែលមិនទាន់បានបង់
  - បុរេប្រទាននិងឥណទាន
  - ឧបករណ៍ដែលមានហត្ថលេខាជនពាក់ព័ន្ធ
- ការកាន់កាប់ភាគហ៊ុនផ្ទាល់ ដែលបានវាយតំលៃតាមតំលៃចុះបញ្ជី
- ការខាតបង្គរ
- ទ្រព្យសកម្មអរូបីរ៍ រួមបញ្ចូលទាំងចំណាយក្នុងការផ្តើមបង្កើត
- ការខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំបញ្ចូលទាំងសវិធានធនសំរាប់បំណុលនិងមូលប័ត្រសង្ស័យ ។

III- សរុប C មូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន = A - B

---

(១)ក្រោយពីដកភាគលាភដែលត្រូវបែងចែក

(២)ឧទាហរណ៍ប្រាក់ចំណេញដែលបានកត់ត្រាតាមគ្រាក្រៅពីប្រាក់ចំណេញនៅចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំ ក្នុងល័ក្ខខ័ណ្ឌដែល ៖

- ប្រាក់ចំណេញនោះត្រូវបានកំណត់ក្រោយពេលបានចុះបញ្ជីនូវចំណាយទាំងអស់ណា ដែលទាក់ទងនឹងគ្រានោះ និងចំណាយរំលស់ព្រមទាំងសវិធានធន និងតំលៃគណនី កែតំរូវ
- ប្រាក់ចំណេញនោះត្រូវបានដកចេញ ពន្ធនិងភាគលាភសុទ្ធដែលនឹងត្រូវបង់ ហើយត្រូវ បានផ្ទៀងផ្ទាត់ដោយស្នងការគណនី

IV- សរុប D ខ្ទង់ត្រូវបូក

- ទុនបំរុងពីការវាយតំលៃឡើងវិញ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- បំណុលបន្ទាប់បន្សំ (Subordinated debt) ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ខ្ទង់ផ្សេងៗទៀត ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា [១] ។

V- សរុប E ខ្ទង់ត្រូវដក

- ភាគកម្មមូលនិធិផ្ទាល់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា

- ខ្ទង់ផ្សេងៗ [២] ។

VI- សរុប F សរុបមូលនិធិផ្ទាល់សុទ្ធ = C + D - E

**ប្រការ ២ :**

មូលនិធិផ្ទាល់សុទ្ធដែលបានគណនាមកនោះ ត្រូវបានយកមកគិតគូរសំរាប់ការគណនានានាអនុបាតប្រុងប្រយ័ត្នទាក់ទងទៅនឹងសាធនភាព ការបែងចែកហានិភ័យ និងហានិភ័យប្តូរប្រាក់ ។

**ប្រការ ៣ :**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

---

(១)ខ្ទង់ផ្សេងៗអាចរួមមានខ្ទង់ទាំងឡាយដូចខាងក្រោមនេះ ៖

. មូលនិធិដែលបានធានាទៅវិញទៅមកយ៉ាងពេញលេញ

. មូលនិធិសាធារណៈដែលបែងចែកសំរាប់ធានាប្រភេទប្រតិបត្តិការឥណទាន

. ឧបត្ថម្ភធនសាធារណៈ ឬឯកជនដែលមិនត្រូវសងវិញ

(២)ឧទាហរណ៍ : សំណាយដែលត្រូវចែងចែកសំរាប់ច្រើនការិយបរិច្ឆេទ

**ប្រការ ៤ :**

**អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។**

**ប្រការ ៥ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសាភិបាល**

**ហត្ថលេខា និងត្រា**

**ជា ចាន់តូ**

★★★